ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ......១៦៩/២២......ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស

## ស្តីពី

## បែបបទ និងនីតិវិធីនៃការផ្តល់វិភាគទានបូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តរបបសន្តិសុខសង្គម។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះវិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ វិភាជន៍បូជាសពគិតទាំងអ្នកដែលជាសមាជិក **ប.ស.ស**. ទាំងសមាជិកជាកាតព្វកិច្ច និងសមាជិកស្ម័គ្រចិត្ត។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានកំណត់និយមន័យដូចខាងក្រោម៖

- ***សិទ្ធិវន្តនៃវិភាជន៍បូជាសព*** សំដៅដល់បុគ្គលដែលមានសិទ្ធិទទួលបានវិភាជន៍បូជាសពមានជាអាទិ៍សិទ្ធិវន្តនៃសោធនឧត្តរជីវី ឬអ្នកចាត់ចែងបូជាសព។
- ***សោធនិកជរាភាព*** សំដៅដល់បុគ្គលដែលបានបំពេញលក្ខខណ្ឌទទួលបានប្រាក់សោធនជរាភាព។
- ***សោធនិកទុព្វលភាព*** សំដៅដល់បុគ្គលដែលបានបំពេញលក្ខខណ្ឌទទួលបានប្រាក់សោធនទុព្វលភាព។
- ***វិភាជន៍បូជាសព*** សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសោធនិកជរាភាព ឬសោធនិកទុព្វលភាព។

## ជំពូកទី២
## ការផ្តល់វិភាជន៍បូជាសព

**ប្រការ៤ .-**

វិភាជន៍បូជាសពផ្នែកប្រាក់សោធន ត្រូវកំណត់ស្មើនឹង៥(ប្រាំ)ខែនៃប្រាក់សោធនចុងក្រោយរបស់សាមីខ្លួន។ វិភាជន៍បូជាសពនៃសោធនិកជរាភាព ឬសោធនិកទុព្វលភាព ត្រូវកំណត់អប្បបរមាស្មើនឹង ២,០០០,០០០ (ពីរលាន)រៀល។

**ប្រការ៥ ..**

សិទ្ធិវន្តនៃវិភាជន៍បូជាសពត្រូវបំពេញទម្រង់ទាមទារ "**តាវកាលិកផ្នែកប្រាក់សោធន**" និងភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ **ប.ស.ស.**។

ទម្រង់នៃការទាមទារ "**តាវកាលិកផ្នែកប្រាក់សោធន**" ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

សិទ្ធិវន្តនៃវិភាជន៍បូជាសពដែលចាត់ចែងបូជាសពរបស់សោធនិកជរាភាព ឬសោធនិកទុព្វលភាពត្រូវបំពេញទម្រង់ទាមទារវិភាជន៍បូជាសពក្នុងអំឡុងពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពរបស់សោធនិក។

**ប្រការ៦ ..**

សិទ្ធិវន្តនៃវិភាជន៍បូជាសព ឬអ្នកចាត់ចែងបូជាសព ត្រូវជូនដំណឹងមក **ប.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ ២(ពីរ)សប្តាហ៍គិតចាប់ពីកាលបរិច្ឆេទនៃសោធនិកជរាភាព ឬសោធនិកទុព្វលភាពទទួលមរណភាព។

វិភាជន៍បូជាសពដែលត្រូវផ្តល់ជូនដល់សិទ្ធិវន្តនៃសោធនឧត្តរជីវី ត្រូវទូទាត់ជាមួយតាវកាលិកសោធនជរាភាព ឬសោធនទុព្វលភាពដែលបានបើកឱ្យដល់សាមីជនក្រោយទទួលមរណភាព។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៧ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ